# អនុសញ្ញាលេខ ១៣៨

## ស្តីពី

## ការកំណត់អាយុអប្បបរមាសំរាប់ការចូលធ្វើការងារ

# អនុសញ្ញាលេខ ១៣៨
# ស្តីពី
# ការកំណត់អាយុអប្បបរមាសំរាប់ការចូលធ្វើការងារ[1]

សន្និសីទសាកលនៃអង្គការការងារអន្តរជាតិ,

ត្រូវបានកោះប្រជុំនៅទីក្រុងហ្សឺណែវដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និងបានបើកសម័យប្រជុំលើកទីហាសិបប្រាំបីរបស់ខ្លួននាថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៧៣, និង

បានសំរេចយល់ព្រមដាក់បញ្ចូលសំណើមួយចំនួនស្តីពី អាយុអប្បបរមាដែលត្រូវអនុញ្ញាតឱ្យចូលធ្វើការទៅក្នុងរបៀបវារៈនៃសម័យប្រជុំ គ្រង់ ៤ ទីបួន, និង

បានឃើញខ្លឹមសារនៃអនុសញ្ញាឆ្នាំ ១៩១៩ ស្តីពី អាយុអប្បបរមា (សំរាប់សហគ្រាសឧស្សាហកម្ម), អនុសញ្ញាឆ្នាំ ១៩២០ ស្តីពីអាយុអប្បបរមា (សំរាប់ការងារនៅសមុទ្រ), អនុសញ្ញាឆ្នាំ ១៩២១ ស្តីពីអាយុអប្បបរមា(សំរាប់ការងារកសិកម្ម), អនុសញ្ញាឆ្នាំ ១៩២១ ស្តីពី អាយុអប្បបរមា (សំរាប់ការងារថៃរក្សា និង ដុតភ្លើងឡចំហាយ ឬម៉ាស៊ីនចំហាយ), អនុសញ្ញាឆ្នាំ ១៩៣២ ស្តីពី អាយុអប្បបរមា (សំរាប់ការងារមិនមែនឧស្សាហកម្ម), អនុសញ្ញាឆ្នាំ ១៩៣៦(អនុសញ្ញាពិនិត្យជាថ្មី) ស្តីពី អាយុអប្បបរមា (សំរាប់ការងារនៅសមុទ្រ), អនុសញ្ញាឆ្នាំ ១៩៣៧ (ពិនិត្យជាថ្មី) ស្តីពីអាយុអប្បបរមា (សំរាប់ការងារឧស្សាហកម្ម), អនុសញ្ញាឆ្នាំ ១៩៣៧ (ពិនិត្យជាថ្មី) ស្តីពី អាយុអប្បបរមា(សំរាប់ការងារមិនមែនឧស្សាហកម្ម), អនុសញ្ញាឆ្នាំ ១៩៥៩ ស្តីពី អាយុអប្បបរមា (សំរាប់អ្នកនេសាទ), និង អនុសញ្ញាឆ្នាំ ១៩៦៥ ស្តីពីអាយុអប្បបរមា(សំរាប់ការងារក្រោមដី), និង

បានពិនិត្យឃើញថាពេលនេះ គឺដល់ពេលដែលត្រូវបង្កើតលិខិតូបករណ៍ទូទៅមួយទាក់ទងនឹងប្រធានបទស្តីពីការកំណត់អាយុអប្បបរមានេះ ហើយដែលជាបណ្តើរៗអាចមកជំនួសគោការណ៍ជាធរមានទៅតាមកំរិតនៃផ្នែកសេដ្ឋកិច្ចនានា ក្នុងគោលបំណងសំដៅឆ្ពោះទៅដល់ការលុបបំបាត់ទាំងស្រុងនៃការងារកុមារ, និង

បានសំរេចថាសំណើទាំងនេះត្រូវតែតាក់តែងចងក្រងជាអនុសញ្ញាអន្តរជាតិមួយ,

អនុម័តនៅថ្ងៃ ទីម្ភៃប្រាំមួយ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបីចំពោះអនុសញ្ញាជាបន្តទៅនេះ ដែលមានឈ្មោះថាអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការកំណត់អាយុអប្បបរមាសំរាប់ការចូលធ្វើការងារ :

---

[1] កាលបរិច្ឆេទចូលជាធរមាន : ១៩ មិថុនា ១៩៧៦

## មាត្រា ១

ចំពោះប្រទេសជាសមាជិកណាដែលអនុសញ្ញានេះបានចូលជាធរមានរួចហើយ គួរព្រមព្រៀងធ្វើគោលនយោបាយជាតិមួយដើម្បីសំដៅធានាចំពោះការលប់បំបាត់ការងារកុមារឱ្យបានប្រកបដោយប្រសិទ្ធិភាព និងសំដៅបង្កើនឱ្យកាន់តែខ្ពស់ឡើងនូវកំរិតអាយុអប្បបរមាសំរាប់ការចូលធ្វើការងារ ឬការចូលប្រកបមុខរបរឱ្យបានសមស្របតាមកំរិតនៃការរីកលូតលាស់ពេញលេញទាំងខាងកម្លាំងកាយ និងសតិបញ្ញារបស់ក្មេង ។

## មាត្រា ២

១. ប្រទេសជាសមាជិកណាមួយដែលផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះ ត្រូវបញ្ជាក់បង្ហាញក្នុងសេចក្តីប្រកាសបន្ថែមលើការផ្តល់សច្ចាប័នរបស់ខ្លួន អំពីកំរិតអាយុអប្បបរមាដែលអនុញ្ញាតឱ្យចូលធ្វើការងារ ឬប្រកបមុខរបរ និងដែលអនុញ្ញាតឱ្យធ្វើការនៅតាមយានដឹកជញ្ជូននានានៅក្នុងដែនដីរបស់ខ្លួន ។ លើកលែងតែបទបញ្ញត្តិដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៨ នៃអនុសញ្ញានេះ គ្មានជនណាម្នាក់ដែលមានអាយុក្រោមការកំរិតនោះអាចត្រូវបានគេប្រើឱ្យប្រកបការងារនៅក្នុងមុខរបរណាក៏ដោយ ។

២. ប្រទេសជាសមាជិកណាមួយដែលផ្តល់សច្ចាប័នអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកការិយាល័យអន្តរជាតិនៃការងារជាបន្តបន្ទាប់តាមរយៈសេចក្តីប្រកាសបន្ថែម ដែលក្នុងសេចក្តីប្រកាសនោះមានបញ្ជាក់អំពីកំរិតអាយុអប្បបរមាដែលកាន់តែខ្ពស់ជាងការកំរិតកាលពីលើកដំបូង ។

៣. កំរិតអាយុអប្បបរមាដូចមានចង្អុលក្នុងវាក្យខ័ណ្ឌ ទី ១ នៃមាត្រានេះ មិនត្រូវតិចជាងអាយុបញ្ចប់ការសិក្សាជាកាតព្វកិច្ច ។ម្យ៉ាងទៀតទោះក្នុងករណីណាក៏ដោយ កំរិតអាយុអប្បបរមានេះមិនត្រូវតិចជាង ១៥ ឆ្នាំទេ ។

៤. ដោយមិនគិតដល់បទបញ្ញត្តិនៃវាក្យខ័ណ្ឌ ទី ៣ នៃមាត្រានេះ ប្រទេសជាសមាជិកណាដែលមានសេដ្ឋកិច្ច និងរចនាសម្ព័ន្ធអប់រំមិនទាន់លូតលាស់ បន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតពាក់ព័ន្ធប្រសិនបើមានអង្គការទាំងនេះ អាចកំរិតអាយុអប្បបរមាជាបឋមត្រឹម ១៤ឆ្នាំ សិនក៏បាន ។

៥. ប្រទេសជាសមាជិកណាដែលបានកំរិតអាយុអប្បបរមាត្រឹម ១៤ ឆ្នាំដោយយោងតាមបទបញ្ញត្តិក្នុងវាក្យខ័ណ្ឌខាងលើ អនុលោមតាមមាត្រា ២២នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារប្រទេសជាសមាជិកនោះត្រូវធ្វើរបាយការណ៍អំពីការអនុវត្តន៍អនុសញ្ញានេះដោយមានដាក់បញ្ចូលនូវសេចក្តីថ្លែងការណ៍បញ្ជាក់អំពី :

(ក) មូលហេតុនៃការកំរិតដូច្នេះ គឺដើម្បីធ្វើឱ្យមានលទ្ធភាពអាចចិញ្ចឹមជីវិតបាន។

(ខ) ការបោះបង់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់បទបញ្ញត្តិនេះចាប់ពីកាលបរិច្ឆេទដែលបានប្រកាសរួចមក ។

## មាត្រា ៣

១. ចំពោះមុខរបរ ឬការងារណា ដែលដោយសារប្រភេទ ឬស្ថានភាពនៃមុខរបរ ឬការងារនោះនៅពេលដែលធ្វើទៅនាំឱ្យមានការប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសតិបញ្ញារបស់ក្មេង អាយុអប្បបរមាដែលអាចឱ្យចូលបំរើក្នុងមុខរបរ ឬការងារទាំងនោះត្រូវកំរិតមិនឱ្យតិចជាង ១៨ ឆ្នាំឡើយ ។

២. ប្រភេទមុខរបរ ឬការងារដូចមានចែងក្នុង វាក្យខ័ណ្ឌ ទី១ នៃមាត្រានេះ ត្រូវកំណត់ដោយច្បាប់ ឬបទបញ្ជានានារបស់ជាតិ ឬក៏ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការរបស់និយោជក និងអង្គការកម្មករនិយោជិតសាមី ប្រសិនបើមានអង្គការទាំងនេះ ។

៣. ដោយមិនគិតដល់បទបញ្ញត្តិនៃវាក្យខ័ណ្ឌ ទី១ នៃមាត្រានេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ក្នុងករណីដែលមានអង្គការទាំងនេះ ច្បាប់ ឬបទបញ្ជានានារបស់ជាតិ ឬក៏អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យមានមុខរបរ ឬការងារសំរាប់ក្មេងដែលមានអាយុត្រឹម ១៦ ឆ្នាំ ក្នុងលក្ខខណ្ឌដែលថាក្មេង ទាំងនោះ ត្រូវបានទទួលការការពារយ៉ាងពេញលេញ ខាងផ្នែកសុខភាព សុវត្ថិភាព ឬសតិបញ្ញា ព្រមទាំងទទួលនូវការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវចំពោះវិជ្ជាជីវៈដែលពាក់ព័ន្ធ។

## មាត្រា ៤

១. ប្រសិនបើមានការចាំបាច់ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ក្នុងករណីដែលមានអង្គការទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចអាចរៀរលែងមិនអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះចំពោះប្រភេទកំណត់នៃមុខរបរ ឬការងារនានា ដែលកាលណាការអនុវត្តន៍នេះអាចនាំឱ្យមានការលំបាកផ្សេងៗកើតឡើង ។

២. ប្រទេសជាសមាជិកណាដែលឱ្យសច្ចាប័នអនុសញ្ញានេះ ត្រូវធ្វើបញ្ជីប្រភេទកំណត់នៃមុខរបរ ឬការងារដែលត្រូវលើក លែង ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះភ្ជាប់ជាមួយនឹងរបាយការណ៍លើកទីមួយរបស់ខ្លួនស្តីពីការអនុវត្តន៍អនុសញ្ញានេះអនុលោមតាមមាត្រា ២២ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ដោយមានធ្វើការបញ្ជាក់ពីមូលហេតុនៃការលើកលែងទាំងនោះផង ។ម្យ៉ាងទៀត ប្រទេសជាសមាជិកនោះ ក៏ត្រូវបញ្ជាក់នៅក្នុងរបាយការណ៍បន្តបន្ទាប់របស់ខ្លួនផងដែរនូវស្ថានភាពនានា នៃច្បាប់ និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រទេសពាក់ព័ន្ធនឹងប្រភេទកំណត់នៃមុខ

របរ ឬការងារដែលត្រូវលើកលែង ព្រមទាំងពាក់ព័ន្ធនឹងវិធានការ ដែលចំពោះវិធានការនេះនាំឱ្យមានផលវិបាកកើតឡើង ឬក៏ត្រូវស្នើចំពោះអនុសញ្ញាឱ្យធ្វើការកំណត់ទាក់ទងនឹងប្រភេទកំណត់នៃមុខរបរ ឬការងារដែលត្រូវលើកលែងទាំងនោះ ។

៣. មុខរបរ ឬការងារដែលគ្របដណ្តប់ដោយមាត្រា ៣ នៃអនុសញ្ញានេះ មិនត្រូវបានវៀរលែងចំពោះការអនុវត្តន៍បទបញ្ញត្តិក្នុងមាត្រានេះទេ ។

## មាត្រា ៥

១. ចំពោះប្រទេសជាសមាជិកណាដែលលទ្ធភាពខាងសេដ្ឋកិច្ច និងរដ្ឋបាលនៅមានកង្វះខាត ប្រទេសនោះអាចរឹតព្រំដែននៃដែនអនុវត្តរបស់អនុសញ្ញានេះបាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ប្រសិនបើមានអង្គការទាំងនេះ។

២. ប្រទេសជាសមាជិកណាដែលបានអនុវត្តតាមបទបញ្ញត្តិនៃវាក្យខ័ណ្ឌ ទី១ នៃមាត្រានេះ ត្រូវបញ្ជាក់នៅក្នុងសេចក្តីប្រកាសបន្ថែមលើការផ្តល់សច្ចាប័នរបស់ខ្លួនអំពីផ្នែកសកម្មភាពសេដ្ឋកិច្ច ឬប្រភេទសហគ្រាសនានាដែលត្រូវអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣.បទបញ្ញត្តិនៃអនុសញ្ញានេះត្រូវអនុវត្តឱ្យបានជាអប្បបរមា ចំពោះអាជីវកម្មដូចតទៅ : អណ្តូងរ៉ែ និងការដ្ឋានវាយថ្ម , កម្មន្តសាល, សំណង់, អគ្គីសនី, ចំការ និងអាជីវកម្មកសិកម្មដទៃទៀតដែលការផលិតជាសំខាន់ គឺសំរាប់គោលដៅពាណិជ្ជកម្ម លើកលែងតែអាជីវកម្មដែលមានលក្ខណៈជាគ្រួសារ និងអាជីវកម្មដែលមានទំហំតូចផលិតសំរាប់តែសេចក្តីត្រូវការក្នុងភូមិស្រុក ហើយមិនមានប្រើប្រាស់កម្មករនិយោជិតជាទៀងទាត់ ។

៤. ប្រទេសជាសមាជិកណាមួយដែលបានរឹតព្រំដែននៃដែនអនុវត្តនៃអនុសញ្ញានេះដោយអនុលោមតាមបទបញ្ញត្តិក្នុងមាត្រានេះ ត្រូវ :

(ក) បង្ហាញនៅក្នុងរបាយការណ៍យោងតាមមាត្រា ២២ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារនូវស្ថានភាពទូទៅនៃមុខរបរ ឬការងាររបស់ក្មេងជំទង់ និងកុមារនៅក្នុងផ្នែកសកម្មភាពសេដ្ឋកិច្ចដែលមិនរាប់ចូល ជាមួយដែនអនុវត្តនៃអនុសញ្ញានេះព្រមទាំងអំពីការរីកចំរើននានាដែលអាចឈានទៅពង្រីកការអនុវត្តន៍ បទបញ្ញត្តិនៃ អនុសញ្ញានេះផង។

(ខ) អាចពង្រីកដែនអនុវតនៃអនុសញ្ញានេះបានគ្រប់ពេល តាមរយៈការធ្វើសេចក្តីប្រកាសជាផ្លូវការមួយផ្ញើជូនទៅអគ្គនាយក នៃការិយាល័យអន្តរជាតិខាងការងារ។

## មាត្រា ៦

អនុសញ្ញានេះមិនអនុវត្តចំពោះការងារដែលធ្វើដោយក្មេង ឬមនុស្សជំទង់នៅក្នុងគ្រឹះស្ថានសិក្សាចំណេះទូទៅ នៅក្នុងសាលាវិជ្ជាជីវៈឬសាលាបច្ចេកទេស ឬការងារនៅក្នុងសហគ្រាសរបស់ក្មេងដែលមានអាយុយ៉ាងតិច ១៤ ឆ្នាំឡើយ ប្រសិនបើការ ងារទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមលក្ខខណ្ឌនានាដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីបានពិ គ្រោះយោបល់ជាមួយអង្គការនិយោជក ឬអង្គការកម្មករនិយោជិតសាមីប្រសិនបើមានអង្គការទាំងនេះ ហើយដែលការងារនេះ គឺជាផ្នែកបតិដ្ឋាននៃ:

(ក) វគ្គនៃការអប់រំ ឬការបណ្តុះបណ្តាល ដែលភាគច្រើនត្រូវទទួលភារៈដោយសាលា ឬស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ។

(ខ) កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមួយដែលធ្វើឡើងដោយភាគច្រើន ឬទាំងស្រុងនៅក្នុងសហគ្រាសមួយ ហើយដែលកម្មវិធីនេះត្រូវបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។

(គ) កម្មវិធីណែនាំ ឬតំរង់ទិសវិជ្ជាជីវៈដែលធ្វើឡើងដើម្បីសំរួលដល់ការជ្រើសរើសមុខរបរណាមួយ ឬជ្រើសរើសមុខវិជ្ជាជីវៈណាមួយ។

## មាត្រា៧

១- ច្បាប់ ឬបទបញ្ញត្តិជាតិអាចអនុញ្ញាតដល់មុខរបរ ឬការងារនៃក្មេងដែលមានអាយុពី ១៣ ដល់ ១៥ ឆ្នាំ ចំពោះការងារ ស្រាល១ ដែលមានលក្ខខណ្ឌដូចខាងក្រោម :

(ក) ការងារដែលមិនមានគ្រោះថ្នាក់ចំពោះសុខភាព និងការអភិវឌ្ឍន៍នៃក្មេង។

(ខ) ការងារណាដែលមិនធ្វើឱ្យប៉ះពាល់ខូចខាតដល់ការរៀនសូត្រ ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលតំរង់ទិសវិជ្ជាជីវៈ ដែលបានយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ឬក៏ការងារដែលមិនបណ្តាលឱ្យប៉ះពាល់ដល់សម្បទាក្នុងការចាប់យក វិជ្ជាជីវៈរបស់ក្មេង។

២- ច្បាប់ ឬបទបញ្ញត្តិជាតិ ក៏អាចអនុញ្ញាតដល់មុខរបរ ឬការងារនៃក្មេងដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ប៉ុន្តែមិនទាន់បានបញ្ចប់កាតព្វកិច្ចសិក្សារបស់ខ្លួននៅឡើយ ចំពោះតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិ នៃចំណុច (ក) និង (ខ) នៃកថាខណ្ឌ ១នៃមាត្រានេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់នូវសកម្មភាពទាំងឡាយណាដែលក្នុងនោះមុខរបរ ឬការងារអាចត្រូវបានទទួលការអនុញ្ញាតក្រោមបទបញ្ញត្តិនៃកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ព្រមទាំងត្រូវកំណត់ចំនួនម៉ោង និងលក្ខខណ្ឌនានាចំពោះមុខរបរ ឬការងារទាំងនេះត្រូវប្រព្រឹត្ត។

៤- ដោយមិនគិតដល់បទបញ្ញត្តិនៃកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ប្រទេសជាសមាជិកណាដែលយល់ថាបទបញ្ញត្តិក្នុងកថាខណ្ឌ ៤ នៃមាត្រា ២ នៅមានសារៈសំខាន់ដែលខ្លួនចាំបាច់ត្រូវបន្តអនុវត្តតទៅទៀត អាចយកអាយុពី ១២ ដល់ ១៣ ឆ្នាំ ជំនួសការកំណត់អាយុពី ១៣ ទៅ ១៥ ឆ្នាំ ដែលមានចែងនៅក្នុងកថាខណ្ឌ ១ និងយកអាយុ ១៤ ឆ្នាំជំនួសការកំណត់អាយុ ១៥ ឆ្នាំដែលមានចែងនៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះ។

## មាត្រា ៨

១-ប្រសិនបើមានវត្តមានអង្គការនិយោជកឬអង្គការកម្មករនិយោជិតសាមី បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអង្គការទាំងនេះមក អាជ្ញាធរមានសមត្ថកិច្ច តាមរយៈការផ្តល់ការអនុញ្ញាតជាបុគ្គល អាចលើកលែងចំពោះការហាមឃាត់លើមុខរបរ ឬការងារដូចដែលបានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ដែលការងារនោះធ្វើឡើងសំរាប់តែការចូលរួមនៅក្នុងការសំដែងសិល្បៈប៉ុណ្ណោះ។

២- ការផ្តល់នូវការអនុញ្ញាតដូច្នេះ ត្រូវមានកំរិតចំនួនម៉ោង និងកំណត់លក្ខខណ្ឌសំរាប់មុខរបរ ឬការងារទាំងនោះផង។

## មាត្រា ៩

១- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ គិតទាំងការផ្តន្ទាទោសសមស្របផង ដើម្បីធានាអនុវត្តប្រកបដោយប្រសិទ្ធភាព នូវបទបញ្ញត្តិនៃអនុសញ្ញានេះ។

២- ច្បាប់ ឬបទបញ្ញត្តិជាតិ ឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវសំរាប់ការអនុវត្តនីបទបញ្ញត្តិដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនូវអនុសញ្ញានេះ។

៣- ច្បាប់ឬបទបញ្ញត្តិជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ឱ្យមានសៀវភៅបញ្ជី ឬឯកសារផ្សេងដទៃទៀតដែលនិយោជកត្រូវមាន និងរក្សាទុក។ សៀវភៅបញ្ជី ឬឯកសារទាំងនេះត្រូវមានចុះឈ្មោះ អាយុ ឬថ្ងៃខែកំណើតរបស់ជនដែលដែលមានអាយុតិចជាង ១៨ ឆ្នាំ ដែលខ្លួនបានប្រើឱ្យធ្វើការ ដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវតាមដែលអាចធ្វើបាន ។

## មាត្រា ១០

១-អនុសញ្ញានេះធ្វើការពិនិត្យឡើងវិញ នូវអនុសញ្ញាឆ្នាំ១៩១៩ស្តីពីអាយុអប្បបរមា(ក្នុងឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩២០ស្តីពីអាយុអប្បបរមា(ការងារក្នុងសមុទ្រ) អនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមា (ក្នុងវិស័យ កសិកម្ម) អនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមា(សំរាប់អ្នករៀបចំបន្ទុកនាវានិងអ្នកដុតឡក្នុងនាវា) អនុសញ្ញា ឆ្នាំ១៩៣២ស្តីពីអាយុអប្បបរមា(ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៣៦(ពិនិត្យឡើងវិញ)ស្តីពីអាយុអប្បបរមា(ការងារសមុទ្រ) អនុសញ្ញាឆ្នាំ១៩៣៧(ពិនិត្យឡើងវិញ)ស្តីពីអាយុអប្បបរមា(ការងារឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៥៩ស្តីពីអាយុអប្បបរមា (សំរាប់អ្នកនេសាទ) អនុសញ្ញាឆ្នាំ១៩៦៥ស្តីពីអាយុអប្បបរមា(ការងារក្រោមដី)។

២-ការចូលជាធរមាននៃអនុសញ្ញានេះមិនបិទការផ្តល់សច្ចាប័នតទៅទៀត ចំពោះអនុសញ្ញាឆ្នាំ១៩៣៦(ពិនិត្យឡើងវិញ)ស្តីពីអាយុអប្បបរមា(ការងារសមុទ្រ) អនុសញ្ញាឆ្នាំ១៩៣៧(ពិនិត្យឡើងវិញ)ស្តីពីអាយុអប្បបរមា(ឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៣៧(ពិនិត្យឡើងវិញ)ស្តីពីអាយុអប្បបរមា(ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៥៩ស្តីពីអាយុអប្បបរមា(អ្នកនេសាទ) និងអនុសញ្ញាឆ្នាំ១៩៦៥ស្តីពីអាយុអប្បបរមា(ការងារក្រោមដី)។

៣- អនុសញ្ញាឆ្នាំ១៩១៩ស្តីពីអាយុអប្បបរមា(ក្នុងឧស្សាហកម្ម ) អនុសញ្ញាឆ្នាំ ១៩២០ស្តីពីអាយុអប្បបរមា(ការងារសមុទ្រ អនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមា(ក្នុងវិស័យកសិកម្ម) អនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមា(អ្នករៀបចំទុកដាក់និងអ្នកដុតឡនាវា) ត្រូវបិទឈប់ឱ្យធ្វើសច្ចាប័នបន្ត នៅពេលណាដែលរាល់ភាគីទាំងអស់បានយល់ព្រមចំពោះការបិទបែបនេះដោយការផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះ ឬដោយការធ្វើសេចក្តីប្រកាសជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ។

៤- នៅពេលដែល អនុសញ្ញានេះចូលជាធរមាន កាតព្វកិច្ចនៃអនុសញ្ញានេះត្រូវបានទទួលយល់ព្រមៈ

(ក) ដោយសមាជិកណាមួយដែលជាដៃគូនៃអនុសញ្ញាឆ្នាំ១៩៣៧(ពិនិត្យឡើងវិញ) ស្តីពីអាយុអប្បបរមា(ឧស្សាហកម្ម) និងដោយយោងតាមការកំរិតអាយុអប្បបរមាមិនតិចជាង១៥ឆ្នាំដូចមានចែងក្នុងមាត្រា២នៃអនុ សញ្ញានេះ ប្រទេស ជាសមាជិកនោះត្រូវចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មលើអនុសញ្ញាឆ្នាំ១៩៣៧នោះ

(ខ) ដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនៃអនុសញ្ញាឆ្នាំ១៩៣២ដែលស្តីពីអយុអប្បបរមា(ក្នុងវិស័យមិនមែនឧស្សាហកម្ម) នោះប្រទេសជាសមាជិកនេះត្រូវចាត់ដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មលើអនុសញ្ញាឆ្នាំ១៩៣២

(គ) ចំពោះមុខរបរដែលមិនមែនជាឧស្សាហកម្ម ដែលមានកំណត់អាយុអប្បបរមានៅក្នុងអនុសញ្ញាឆ្នាំ១៩៣៧ (អនុសញ្ញាពិនិត្យឡើងវិញ) គឺកាតព្វកិច្ចដែលបានយល់ព្រមដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញានោះ និងដោយយោងតាមការកំរិតអាយុអប្បបរមាមិនតិចជាង១៥ឆ្នាំដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ប្រទេសនោះនឹងត្រូវចាត់ទុកដោយពេញច្បាប់ថាបានធ្វើប្បដិបត្តិកម្មចំពោះអនុសញ្ញាឆ្នាំ១៩៣៧

(ឃ) ចំពោះមុខរបរនៅសមុទ្រ គឺកាតព្វកិច្ចដែលបានយល់ព្រមដោយប្រទេសជាមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញាឆ្នាំ ១៩៣៦ (អនុសញ្ញាបុនរាព្រឹត្ត) ដែលស្តីពីអាយុអប្បបរមា (ការងារក្នុងសមុទ្រ) និងដោយអនុលោមតាមការកំរិតអាយុអប្បបរមាមិនតិចជាង១៥ឆ្នាំ ដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ឬបើប្រទេសសមាជិកនោះកំណត់យកមាត្រា ៣នៃអនុសញ្ញានេះដើម្បីអនុវត្តការងារនៅក្នុង សមុទ្រ ប្រទេសនោះនឹងត្រូវចាត់ដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្ម ចំពោះអនុសញ្ញាខាងលើ

(ង) ចំពោះការងារនេសាទសមុទ្រ គឺកាតព្វកិច្ចដែលបានយល់ព្រមដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូអនុសញ្ញាឆ្នាំ១៩៥៩ស្តីពីអាយុអប្បបរមា (ការងារនេសាទសមុទ្រ) និងដោយផ្អែកតាមការកំរិតអាយុអប្បបរមាមិនតិចជាង១៥ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ឬបើប្រទេសនោះកំណត់យកមាត្រា ៣ នៃអនុសញ្ញានេះសំរាប់មុខរបរនេសាទសមុទ្រ នោះប្រទេសជាសមាជិកនោះនឹងត្រូវចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ ១៩៥៩

(ច) ដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញាឆ្នាំ១៩៦៥ស្តីពីអាយុអប្បបរមា (ការងារក្រោមដី) និងដោយផ្អែកតាមការកំណត់អាយុអប្បបរមាមិនឱ្យតិចជាងអាយុដែលមាកំណត់នៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬបើប្រទេសនោះកំណត់យកអាយុសំរាប់ការងារក្រោមដីតាមបទបញ្ញត្តិនៃមាត្រា ៣ របស់អនុសញ្ញានេះ នោះប្រទេសជាសមាជិកនោះត្រូវបានចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩៦៥។

៥- ការយល់ព្រមចំពោះកាតព្វកិច្ចនៃអនុសញ្ញានេះ :

(ក) ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩១៩ស្តីពីអាយុអប្បបរមា (ការងារឧស្សាហកម្ម) អនុលោមតាមមាត្រា១២នៃអនុសញ្ញានេះ

(ខ) ចំពោះវិស័យកសិកម្ម ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមា (វិស័យកសិកម្ម) អនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ

(គ) ចំពោះការងារនៅសមុទ្រ ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩២០ស្តីពីអាយុអប្បបរមាសំរាប់ការងារនៅសមុទ្រដោយអនុលោមតាមមាត្រា ១០ នៃអនុសញ្ញានេះ ព្រមទាំអនុសញ្ញាឆ្នាំ១៩២១ស្តីពីអាយុអប្បបរមារបស់អ្នករៀបចំនាវា និងអ្នកដុតឡចំហាយក្នុងនាវា ដោយអនុលោមតាមមាត្រា១២នៃអនុសញ្ញានេះ។

## មាត្រា ១១

សច្ចាប័នជាផ្លូវការនៃអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាង ការងារដើម្បីចុះ បញ្ជិកា ។

## មាត្រា ១២

១. អនុសញ្ញានេះត្រូវចាត់ទុកជាកាតព្វកិច្ចចំពោះតែសមាជិកនៃអង្គការអន្តរជាតិខាងការងារទាំងឡាយណា ដែលការផ្តល់សច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជិការួចហើយដោយអគ្គនាយកនៃអង្គការនេះ ។

២. អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ប្រទេសជាសមាជិកចំនួនពីរត្រូវបានទទួលការចុះបញ្ជិកាពីអគ្គនាយកនៃការិយាល័យអង្គការអន្តរជាតិខាង ការងាររួចហើយ ។

៣. បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមានសំរាប់ប្រទេសជាសមាជិកណាមួយ ក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ប្រទេសនោះបានទទួលការចុះបញ្ជិការួចហើយ ។

## មាត្រា ១៣

១. ប្រទេសជាសមាជិកណាមួយដែលបានផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះរួចហើយ អាចធ្វើអប្បជិបត្តិកម្មវិញបាននៅក្នុងឆ្នាំបន្ទាប់ពីអំឡុងពេលដប់ឆ្នាំបានកន្លងផុត ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរ មានលើកទីមួយនៃអនុសញ្ញានេះ តាមរយៈលិខិតជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីអគ្គនាយកនេះចុះបញ្ជិកា ។ អប្បជិបត្តិកម្មនេះនឹងមិនមានអនុភាពទេរហូតរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកា ។

២. ប្រទេសជាសមាជិកណាដែលបានផ្តល់សច្ចាប័នអនុសញ្ញានេះរួចហើយ ប៉ុន្តែនៅក្នុងឆ្នាំបន្ទាប់ពីការផុតរលត់នៃរយៈពេលដប់ឆ្នាំដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនបានអនុវត្តសិទ្ធិនៃអប្បជិបត្តិកម្មដូចដែលបានកំណត់ក្នុងមាត្រានេះទេ នឹងត្រូវរង់ចាំក្នុងរយៈពេលដប់ឆ្នាំថ្មីជាបន្តទៀត ។ ហើយបន្ទាប់ពីនោះមក អាចធ្វើអប្បជិបត្តិកម្មក្រោយការកន្លងផុតទៅនៅ រៀងរាល់រយៈពេលដប់ឆ្នាំតាមន័យនៃមាត្រានេះ ។

## មាត្រា ១៤

១. អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវជូនដំណឹងទៅគ្រប់ប្រទេសជាសមាជិកទាំងអស់នៃអង្គការអន្តរ ជាតិខាងការងារអំពីការចុះបញ្ជិកានៃរាល់ការផ្តល់សច្ចាប័ននិងអប្បជិបត្តិកម្មរបស់ប្រទេសជាសមា ជិកនានានៃអង្គការនេះ ។

២. នៅពេលជូនដំណឹងអំពីការផ្តល់សច្ចាប័នទីពីរលើអនុសញ្ញានេះ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវក្រើនរំលឹកចំពោះប្រទេសជាសមាជិកទាំងអស់នូវកាលបរិច្ឆេទដែលអនុសញ្ញានេះនឹងត្រូវចូលជាធរមាន ។

## មាត្រា ១៥

អនុលោមតាមមាត្រា ១០២ នៃធមមនុញ្ញរបស់អង្គការសហប្រជាជាតិ អគ្គនាយកនៃការិយាល័យ អន្តរជាតិខាងការងារ ត្រូវផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដើម្បីចុះបញ្ជិកានូវរបាយការណ៍លំអិតអំពីការផ្តល់សច្ចាប័ន និងលិខិតធ្វើអប្បដិបត្តិកម្មដែលបានចុះបញ្ជិកាដោយអគ្គនាយកនេះរួចហើយស្របតាមខ្លឹមសារ នៃបទប្បញ្ញត្តិនៃមាត្រាខាងលើ ។

## មាត្រា ១៦

នៅពេលណាដែលពិនិត្យឃើញថាមានការចាំបាច់ ក្រុមប្រឹក្សាភិបាលនៃអង្គការអន្តរជាតិខាងការងារត្រូវដាក់ជូនសន្និសីទសាកលនូវរបាយការណ៍ស្តីពីដំណើរប្រព្រឹត្តទៅនៃអនុសញ្ញានេះ ព្រមទាំងបញ្ជាក់ពីគោលបំណងនៃការបញ្ចូលទៅក្នុងរបៀបវារៈនសន្និសីទនេះនូវបញ្ហាពាក់ព័ន្ធនឹងការធ្វើបុនរាព្រឹត្តទាំងស្រុង ឬដោយផ្នែកខ្លះចំពោះ អនុសញ្ញានេះ ។

## មាត្រា ១៧

១.ក្នុងករណីដែលសន្និសីទសាកលអនុម័តអនុសញ្ញាថ្មីដែលធ្វើការពិនិត្យឡើងវិញទាំងស្រុង ឬដោយផ្នែកចំពោះអនុសញ្ញានេះ និងវៀរលែងតែអនុសញ្ញាថ្មីនោះមានកំណត់បទប្បញ្ញត្តិផ្សេងពីនេះ :

(ក) ការផ្តល់សច្ចាប័ននៃសមាជិកណាមួយចំពោះអនុសញ្ញាថ្មីដែលបានធ្វើការពិនិត្យឡើងវិញហើយនោះ នឹងត្រូវមានន័យពេញលេញ តាមច្បាប់ថាប្រទេសជាសមាជិកនោះបានធ្វើអប្បដិបត្តិកម្មចំពោះអនុសញ្ញានេះជាស្វ័យប្រវត្តិ ដោយមិនមានគិតដល់បទ បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ខាងលើ និងប្រសិនបើក្នុងពេលនោះ អនុសញ្ញាថ្មីនេះត្រូវបានចូលជាធរមានរួចហើយ ។

(ខ) ចាប់ពីពេលដែលអនុសញ្ញាថ្មីនោះចូលជាធរមាន អនុសញ្ញានេះនឹងលែងបើកឱ្យប្រទេសជាសមាជិកនានា ផ្តល់សច្ចាប័នទៀតហើយ ។

២. ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនឹងនៅជាធរមានជាដរាប ទាំងទំរង់និងខ្លឹមសារចំពោះ ប្រទេសជាសមាជិកណាដែលបានឱ្យសច្ចាប័នរួចហើយ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាដែលបានពិនិត្យឡើងវិញនៅឡើយ ។

## មាត្រា ១៨

អត្ថបទបកប្រែ ជាភាសាអង់គ្លេស និង បារាំងនៃអនុសញ្ញានេះមានតំលៃជាផ្លូវការដូចគ្នា ។